**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តកំពង់ចាម**

លេខ. ១២១៥/១៦.សខ៣ កំពង់ចាម ថ្ងៃទី០៦...ខែកញ្ញា...ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧

សាលាខេត្តកំពង់ចាម មានកិត្តិយសសូមជម្រាបដល់អ្នកទទួលការ ទាំងអស់ឲ្យបានជ្រាបថា៖ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ សាលាខេត្តកំពង់ចាម នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧។អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃនៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ...។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំហើយត្រូវមានបទពិសោធន៍ការអនុវត្តគម្រោង ទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច ០២ក្នុងអំឡុងពេល ០៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើ លក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការ ជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការសម្រាប់ឆ្នាំ២០១៧ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការ និងវិនិយោគ ចាប់ពីថ្ងៃទី ០៦ ខែ កញ្ញា រហូតដល់ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៦ រៀងរាល់ម៉ោងធ្វើការ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគខេត្ត ឬដោយទាញយកបានពីគេហទំព័ររបស់ គ ជ អ ប (www.ncdd.gov.kh) ដោយឥតបង់ថ្លៃ។

ការប្រកាសជូនដំណឹងស្តីពីការដាក់ពាក្យចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ២០១៧ មានបិទផ្សាយនៅលើក្តារព័ត៌មាន សាលាខេត្តកំពង់ចាម។

**អភិបាលខេត្ត**

**លន់_លឹមថៃ**